**សេចក្តីថ្លែងការណ៍បញ្ចប់បេសកកម្ម**
អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ
ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅប្រទេសកម្ពុជា
លោកស្រី **សាស្ត្រាចារ្យ រ៉ូណា ស្មីត**

រាជធានីភ្នំពេញ ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៨

ពិនិត្យផ្ទៀងផ្ទាត់ទៅនឹងសេចក្តីថ្លែងផ្ទាល់មាត់

កាលពីមួយខែមុន ខ្ញុំបានរាយការណ៍ទៅក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ស្តីពីស្ថានភាពសិទ្ធិមនុស្ស ការបោះឆ្នោត និងលំហប្រជាធិបតេយ្យនៅប្រទេសកម្ពុជា។ ខ្ញុំលើកឡើងពីកង្វល់ និងអនុសាសន៍របស់ខ្ញុំ ដែលបានលើកឡើងនៅក្នុងរបាយការណ៍នោះ ហើយនិងរបាយការណ៍បន្ថែម )A/HRC/39/73 និង A/HRC/39/73/Add.1)។

ឥឡូវនេះ ខ្ញុំបានបញ្ចប់ដំណើរទស្សនកិច្ចលើកទីប្រាំមួយ របស់ខ្ញុំ នៅព្រះរាជាណាចក្រកម្ពុជា ហើយ ក្នុងនាមជាអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សនៅប្រទេសកម្ពុជា។ ខ្ញុំសូមអរគុណរដ្ឋាភិបាលដែលបានអញ្ជើញខ្ញុំមកធ្វើទស្សនកិច្ច និងឆន្ទៈរបស់មន្ត្រីជាច្រើនរបស់រដ្ឋាភិបាលដែលមានបំណង់ជួបពិភាក្សាដោយចំហជាមួយខ្ញុំអំពីសិទ្ធិសេរីភាពនិងការអភិវឌ្ឍប្រកបដោយចីរភាពនៅប្រទេសកម្ពុជា។ ខ្ញុំសូមសំដែងការកោតសរសើរចំពោះការខិតខំប្រឹងប្រែង និងការលះបង់របស់បុគ្គលិកទាំងអស់របស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា និងនៅទីក្រុងហ្សឺណែវ ដែលបានរៀបចំនិងគាំទ្រដល់បេសកកម្មនេះ ប្រកបដោយសមត្ថភាព ។

ក្នុងអំឡុងពេលបំពេញបេសកកម្មនេះ ខ្ញុំមានបុព្វសិទ្ធិជួបជាមួយមន្ត្រីជាន់ខ្ពស់មួយចំនួន ជាពិសេសសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ, ឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តម ជា សុផារ៉ា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ឯកឧត្តម អង្គ វង្សវឌ្ឍនា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌, ឯកឧត្តម ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មាន, ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន, ឯកឧត្តម វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ឯកឧត្តម កែវ រ៉េមី ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា, លោកជំទាវ អៀត សុភា រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, ឯកឧត្តម ប៉ូច ប៊ុនណាក់ រដ្ឋលេខាធិការក្រសួងផែនការ, លោកជំទាវ ហង្ស លីណា អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ, និង ឯកឧត្តម រិទ្ធ វុទ្ធី អគ្គលេខាធិការរង នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ខ្ញុំបានជួបផងដែរជាមួយអ្នកពាក់ព័ន្ធជាច្រើន រួមមានតំណាងសង្គមស៊ីវិល និងគណបក្សនយោបាយ, សហគមន៍ការទូត និងក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា។

ខ្ញុំសូមថ្លែងអំណរគុណចំពោះអស់លោកលោកស្រីទាំងអស់ ដែលបានឆ្លៀតពេលចែករំលែកការយល់ដឹងនិងព័ត៌មានជាមួយខ្ញុំ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំត្រូវបានបដិសេធម្តងទៀត ក្នុងចូលជួបជនដែលត្រូវដាក់ឱ្យស្ថិតនៅក្រោមការឃុំខ្លួន ជាពិសេសនៅក្នុងឱកាសនេះគឺ ឯកឧត្តម កឹម សុខា ដែលបច្ចុប្បន្នគាត់កំពុងស្ថិតក្នុងការឃុំខ្លួនក្នុងផ្ទះ ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។ ខ្ញុំរំលឹករដ្ឋាភិបាលពីការពិភាក្សាលើកមុនៗថា ក្នុងនាមជាអ្នកជំនាញឯករាជ្យមួយរូប ដែលតែងតាំងដោយក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ខ្ញុំគួរតែត្រូវបានអនុញ្ញាតឲ្យចូលជួបជាលក្ខណៈឯកជន ជាមួយជនទាំងឡាយ ដែលត្រូវដាក់ឱ្យស្ថិតនៅក្រោមការឃុំខ្លួន។

ខ្ញុំសូមឆ្លៀតឱកាសនេះ បំភ្លឺអំពីចរិតលក្ខណៈនៃអាណត្តិរបស់ខ្ញុំ ព្រោះដោយសារកន្លងមកមានការយល់ច្រឡំខ្លះៗនៅក្នុងអំឡុងពេលបំពេញបេសកកម្មលើកនេះ។ ខ្ញុំជាអ្នកជំនាញឯករាជ្យមួយរូបដែលត្រូវបានតែងតាំងដោយក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ នៅទីក្រុងហ្សឺណែវ ធ្វើជាអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅប្រទេសកម្ពុជា។ ការណ៍នេះមានន័យថា ខ្ញុំត្រូវឆ្លើយតបចំពោះរដ្ឋជាសមាជិកនៃក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ។ ខណៈពេលដែលបុគ្គលិកនៃការិយាល័យឧត្តមស្នងអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ផ្តល់ការគាំទ្រដល់ដំណើរការងាររបស់ខ្ញុំ ខ្ញុំមិនមានឋានៈជាបុគ្គលិករបស់អង្គការសហប្រជាជាតិទេ។ ហេតុដូចនេះហើយ លក្ខខណ្ឌដែលមានចែងក្នុងអនុស្សរណៈស្តីពីការយោគយល់គ្នា ដែលបានចុះហត្ថលេខានាពេលថ្មីៗនេះ រវាងឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស និងរដ្ឋាភិបាល មិនចងកាតព្វកិច្ចមកលើរូបខ្ញុំឡើយ។ ទោះជាយ៉ាងណា ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះការបន្តអនុស្សរណៈយោគយល់គ្នានេះ និងឆន្ទៈរបស់រដ្ឋាភិបាលក្នុងការធ្វើការយ៉ាងជិតស្និទ្ធជាមួយការិយាល័យឧត្តមស្នងអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ប្រចាំប្រទេសកម្ពុជា ដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស។

* * *

ចំពោះបេសកកម្មនេះ ខ្ញុំបានជ្រើសរើសផ្តោតលើការធ្វើមូលដ្ឋានរូបនីយកម្មនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ និងយុទ្ធសាស្ត្រពាក់ព័ន្ធនានា ជាពិសេសគោលដៅអភិវឌ្ឍន៍ទី១៦ ស្តីពី «សន្តិភាព យុត្តិធម៌ និងស្ថាប័នរឹងមាំ»។ ហេតុអ្វី?

បច្ចុប្បន្ននេះ ប្រទេសកម្ពុជាស្ថិតនៅក្នុងដំណាក់កាលអភិវឌ្ឍន៍ផ្សេងមួយទៀត។ បន្ទាប់ពីទទួលបានកំណើនសេដ្ឋកិច្ចដ៏រឹងមាំ និងវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការកាត់បន្ថយភាពក្រីក្រក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ ប្រទេសកម្ពុជាមានចក្ខុវិស័យប្រែក្លាយទៅជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅត្រឹម ឆ្នាំ២០៥០។ ដើម្បីជួយបង្ហាញផ្លូវឆ្ពោះទៅរកការសម្រេចបាននូវចក្ខុវិស័យនេះ រដ្ឋាភិបាលបានអនុម័តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី IV និងកំពុងរៀបចំបញ្ចប់នូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការមូលដ្ឋានរូបនីយកម្មសម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ **ខ្ញុំសូមលើកទឹកចិត្តដល់រដ្ឋាភិបាលឱ្យបញ្ចប់យ៉ាងឆាប់រហ័ស និងធ្វើការផ្សព្វផ្សាយផែនការមូលដ្ឋានរូបនីយកម្មនេះ។**

ការលើកកម្ពស់ និងការពារសិទ្ធិមនុស្សគឺជាសមាសធាតុដ៏សំខាន់សម្រាប់យុទ្ធសាស្ត្រ និងផែនការទាំងអស់នេះ ហើយក៏សំខាន់សម្រាប់ឆ្ពោះទៅរកចក្ខុវិស័យឆ្នាំ ២០៥០។ ឧទាហរណ៍ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទីIV បានតម្កល់អភិបាលកិច្ចល្អជាស្នូលនៃយុទ្ធសាស្ត្រ។ អភិបាលកិច្ចល្អ តម្រូវឲ្យមាននូវស្ថាប័នរឹងមាំ និងបើកទូលាយ ហើយដំណើរការស្របតាមគោលការណ៍សិទ្ធិមនុស្ស ដែលរួមមាន សិទ្ធិទទួលបានព័ត៌មាន តម្លាភាព ការចូលរួមជាសាធារណៈក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងគណនេយ្យភាពរបស់មន្ត្រីសាធារណៈ និងមន្ត្រីរាជការ ការទទួលបានយុត្តិធម៌ដោយមានការគាំទ្រពីសេរីភាពសារព័ត៌មាន និងសង្គមស៊ីវិលដែលធ្វើការងារយ៉ាងរស់រវើក ប្រកបដោយសេរីភាព និងនវានុវត្តន៍។ ជាបន្ថែម ដើម្បីកម្ពុជាសម្រេចបានចក្ខុវិស័យឆ្នាំ២០៥០ ការសិក្សានានាបង្ហាញថាកំនើនសេដ្ឋកិច្ចត្រូវមានបរិយាបន្ន និងសមធម៌ច្រើនថែមទៀត ដើម្បីជាប្រយោជន៍នៃការអភិវឌ្ឍប្រកបដោយចីរភាព។ ការណ៍នេះមានន័យថា «មិនមានមនុស្សណាម្នាក់ត្រូវបានគេទុកចោលឡើយ» ដោយក្នុងនោះរួមទាំង ស្ត្រី អ្នកក្រីក្រ អ្នកដែលស្ថិតជិតបន្ទាត់ក្រីក្រ អ្នកដែលមិនមានភាពជាតំណាង និងអ្នកមិនត្រូវបានយកចិត្តទុកដាក់ក្នុងសង្គម និងអ្នកទាំងឡាយដែលរស់នៅក្នុងស្ថានភាពងាយរងគ្រោះ។

គោលការណ៍សិទ្ធិមនុស្ស ដែលរួមមាន ការចូលរួម សមភាព ការមិនរើសអើង គណនេយ្យភាពត្រូវបានតំកល់ក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ អាស្រ័យហេតុនេះ វាជាកត្តាសំខាន់ដែលគោលការណ៍សិទ្ធិមនុស្សទាំងនេះត្រូវបានរួមបញ្ចូលនៅក្នុងការតាក់តែង ការអនុវត្ត ហើយនិងការពិនិត្យតាមដាន និងវាយតម្លៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍

ប្រកបដោយចីរភាពរបស់កម្ពុជា និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ។ តាមរូបភាពជាច្រើន គោលដៅអភិវឌ្ឍន៍ទី១៦ ផ្តោតលើស្ថាប័នដែលរឹងមាំ មានប្រសិទ្ធភាព គណនេយ្យភាព និងបរិយាបន្ន ហើយតម្លាភាព និងការទទួលបានយុត្តិធម៌ គឺជាយានសម្រាប់សម្រេចគោលដៅនេះ។

ជាក់ស្តែង គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពមិនមែនសម្រាប់ជំនួសការការពារនិងលើកកម្ពស់សិទ្ធិមនុស្សនោះទេ ប៉ុន្តែវាជាប្រព័ន្ធសម្រាប់បំពេញបន្ថែម។ លើផ្នែកមួយ សិទ្ធិមនុស្សធ្វើឱ្យវិស័យជាច្រើននៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពអាចអនុវត្តបានស៊ីជម្រៅ និងស្របច្បាប់។ លើផ្នែកផ្សេងទៀត គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ផ្តល់នូវកម្មវិធីដែលជួយដល់ការអនុវត្តបទដ្ឋានសិទ្ធិមនុស្ស។

ខណៈធ្វើការវិភាគចំណុចដៅ និងសូចនាករ ដែលមាននៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ជាមួយនឹងកាតព្វកិច្ចសិទ្ធិមនុស្សរបស់កម្ពុជា ខ្ញុំក៏រំលឹកឡើងវិញពីអនុសាសន៍នានា ដែលខ្ញុំបានផ្តល់កាលពីលើកមុនៗមកទាក់ទងនឹង សិទ្ធិដីធ្លី ឯករាជ្យភាពរបស់ប្រព័ន្ធតុលាការ និងការទទួលបានយុត្តិធម៌ ប្រព័ន្ធពន្ធនាគារ សិទ្ធិនយោបាយ ការទទួលបានសេវានានា និងការមិនរើសអើង។ ខ្ញុំមានឱកាសពិនិត្យមើលឡើងវិញលើបញ្ហាទាំងនេះ អំឡុងពេលនៃទស្សនកិច្ចនេះ ។

ដើម្បីវាយតម្លៃបានប្រសើរនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ខ្ញុំបានផ្តោតលើបញ្ហាបីដែលពាក់ព័ន្ធគ្នាគឺ គណនេយ្យភាព ការចូលរួម និងការមិនទុកមនុស្សណាម្នាក់ចោល ។

## ការចូលរួម

គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងបទដ្ឋានសិទ្ធិមនុស្សតម្រូវឲ្យមាន**ការចូលរួមប្រកបដោយអត្ថន័យក្នុងកិច្ចការអភិបាលកិច្ច និងអភិវឌ្ឍន៍**។ ការចូលរួមនេះតម្រូវឲ្យមានជាលក្ខណៈផ្លូវការពាក់ព័ន្ធនឹងសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះបោះឆ្នោត ប៉ុន្តែក៏តម្រូវឲ្យមានផងដែរតាមរយៈមធ្យោបាយផ្សេងទៀត ដូចជា ការចូលរួមប្រកបដោយអត្ថន័យក្នុងការអភិវឌ្ឍ ការអនុវត្ត និងការពិនិត្យតាមដានការអនុវត្តច្បាប់ គោលនយោបាយ និងថវិកា។

ខ្ញុំមានការជំរុញលើកទឹកចិត្តតាមរយៈដំណើរការនៃការចូលរួមក្នុងការបង្កើត**សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន** នាពេលថ្មីៗនេះ ហើយខ្ញុំសូមអំពាវនាវដល់រដ្ឋាភិបាលបន្តធ្វើដូច្នេះ តាមរយៈការអនុម័ត និងការអនុវត្តសេចក្តីព្រាងច្បាប់ចុងក្រោយ។ វិធីសាស្រ្តចូលរួមក្នុងការបង្កើតច្បាប់ដូចនេះ អាចចម្លងយកទៅប្រើប្រាស់នៅតាមវិស័យដទៃទៀត ហើយក៏អាចចម្លងយកទៅប្រើប្រាស់ផងដែរក្នុងការពិនិត្យឡើងវិញនូវច្បាប់ទាំងឡាយនាពេលថ្មីៗនេះ។ ខ្ញុំមានការជំរុញលើកទឹកចិត្តពេលបានទទួល

ព័ត៌មានថា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបង្ហាញពីបំណងរបស់ខ្លួន ក្នុងការពិគ្រោះយោបល់បន្ថែមទៀតជាទៀងទាត់ ជាមួយសង្គមស៊ីវិលស្តីពីកំណែទម្រង់ច្បាប់។

ខ្ញុំសូមស្វាគមន៍ចំពោះការបង្កើតនាពេលថ្មីៗនេះនូវ**ក្រុមការងាររដ្ឋាភិបាល** ក្រោមកិច្ចដឹកនាំរបស់ក្រសួងមហាផ្ទៃ ដើម្បីពិគ្រោះយោបល់ជាទៀងទាត់ជាមួយសង្គមស៊ីវិល។ វានឹងកាន់តែមាន សារសំខាន់ទៅទៀតនៅពេលក្រុមការងារថ្មីនេះអាចអនុម័តវិធីសាស្រ្តធ្វើការងារច្បាស់លាស់ និងមានតម្លាភាព សំដៅបង្កឱ្យមានបរិយាកាសប្រកបដោយបរិយាបន្នជាមួយអង្គការសង្គមស៊ីវិលក្នុងកិច្ចការពិគ្រោះយោបល់ តាមរយៈការធ្វើការងារជាមួយអង្គការសង្គមស៊ីវិលទាំងនោះក្នុងការរៀបចំរបៀបវារៈកិច្ចប្រជុំនានា ផ្តល់ពេលវេលាឲ្យពួកគេរៀបចំខ្លួនសម្រាប់កិច្ចប្រជុំ និងអនុញ្ញាតឲ្យពួកគេមានតួនាទីក្នុងការតាមដាននិងបន្តធ្វើការងារលើបញ្ហាទាំងឡាយដែលបានលើកឡើងក្នុងក្រុមការងារនេះ។ ខ្ញុំសូមលើកទឹកចិត្តដល់គូភាគីឲ្យមានស្មារតីសហការគ្នាពិតប្រាកដ។ អង្គការសង្គមស៊ីវិលនឹងត្រូវបានធានាថាពួកគេអាចសហការជាមួយក្រុមការងារនេះ យ៉ាងសកម្ម និងប្រកបដោយអត្ថន័យ ដោយគ្មានការ ភិតភ័យចំពោះការសងសឹកណាមួយពីគ្រប់ជាន់ថ្នាក់ រាប់ទាំងថ្នាក់មូលដ្ឋានផងដែរ។

ចាប់តាំងពីឆ្នាំមុន ខ្ញុំបានទទួលរបាយការណ៍ជាច្រើនអំពីសកម្មភាពរបស់អង្គការសង្គមស៊ីវិលដែលត្រូវបានបញ្ឈប់ និងត្រូវបានរារាំង តាមសេចក្តីណែនាំដែលចេញដោយក្រសួងមហាផ្ទៃកាលពីខែតុលា ឆ្នាំ២០១៧ ដែលតម្រូវឱ្យអង្គការសង្គមស៊ីវិល ត្រូវជូនដំណឹងជាមុនអំពីសកម្មភាពរបស់ពួកគេ។ **ហេតុនេះ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះសេចក្តីណែនាំថ្មី ដែលចេញដោយក្រសួងមហាផ្ទៃ ណែនាំទៅអាជ្ញាធរថ្នាក់ក្រោមជាតិកាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨** ដែលរដ្ឋមន្ត្រីបានប្រាប់ខ្ញុំយ៉ាងច្បាស់លាស់ថា សេចក្តីណែនាំថ្មីនេះលុបចោលលិខិតដែលចេញកាលពីខែតុលា ឆ្នាំ២០១៧។ សេចក្តីណែនាំថ្មីរំលឹកអាជ្ញាធរមូលដ្ឋានថា ទាំងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះបញ្ជីក្រោមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងសហគមន៍មូលដ្ឋានដែលមិនចុះបញ្ជីមានសិទ្ធិ និងសេរីភាពពេញលេញ ធ្វើសកម្មភាពស្របតាមច្បាប់កម្ពុជា។ ខ្ញុំ**សូមឱ្យរាជរដ្ឋាភិបាលចាត់គ្រប់វិធានការចាំបាច់ ដើម្បីធានាឱ្យមានការអនុវត្តស្របតាមសេចក្តីណែនាំថ្មីនេះឱ្យបានត្រឹមត្រូវនៅគ្រប់ជាន់ថ្នាក់។**

ទន្ទឹមនឹងនេះ ខ្ញុំទទួលដំណឹងថា អង្គការសង្គមស៊ីវិល នៅតែប្រឈមនឹងបន្ទុកយ៉ាងធ្ងន់ទាក់ទងនឹងលក្ខខណ្ឌតម្រូវតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល, ច្បាប់សហជីព បទប្បញ្ញត្តិពន្ធដារ និងច្បាប់ដទៃទៀត។ ខ្ញុំក៏បានដឹងដែរថា លក្ខខណ្ឌតម្រូវទាំងនេះ មិនត្រូវបានអនុវត្តដោយស្មើភាពគ្នាទេ ហើយថាលក្ខខណ្ឌទាំងនេះ ត្រូវបានអនុវត្តដោយឡែកៗពីគ្នាយ៉ាងតឹងរឹង និងកាន់តែលំអិតចំពោះអង្គការមួយចំនួន។ ហេតុដូច្នេះ ខ្ញុំសូមលើកទឹកចិត្តឱ្យរាជរដ្ឋាភិបាល **ធ្វើការពិនិត្យឡើងវិញពីក្របខ័ណ្ឌច្បាប់ និងក្របខ័ណ្ឌរដ្ឋបាល** ដែលយកមកអនុវត្តនៅក្នុងករណីនេះ ដោយធ្វើការ

ពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិល និងអង្គការសហប្រជាជាតិ ដើម្បីធានាថា ការអនុវត្តធ្វើឡើងស្របតាមគោលបំណងរបស់ច្បាប់ ដោយមិនមានការបន្ថែមបន្ទុកមិនត្រឹមត្រូវដល់ពួកគេ ហើយថាច្បាប់ទាំងនេះ ត្រូវបានយកមកអនុវត្តដោយតម្លាភាព និងត្រឹមត្រូវ។

ឆ្លើយតបតាមការស្នើសុំ ខ្ញុំបានជួបប្រជុំជាមួយគណបក្សនយោបាយមួយចំនួនដែលបានចូលរួមបង្កើត**ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់** បង្កើតឡើងដោយព្រះរាជក្រឹត្យកាលពីខែសីហា។ ខ្ញុំជ្រាបថា ឧត្តមក្រុមប្រឹក្សាកំពុងតែចុះធ្វើការស្រាវជ្រាវបញ្ហាកង្វល់នានា ហើយត្រូវរាយការណ៍ជូននាយករដ្ឋមន្ត្រី។ តំណាងរដ្ឋាភិបាលបានជំរាបជូនខ្ញុំថា ឧត្តមក្រុមប្រឹក្សានេះត្រូវបានបង្កើតឡើង ដើម្បីដោះស្រាយចំពោះការមិនមានគណបក្សប្រឆាំងដែលបានជាប់ឆ្នោតអង្គុយក្នុងរដ្ឋសភា។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំសូមគូសបញ្ជាក់ជាថ្មីពីសេចក្តីកង្វល់ដែលខ្ញុំបានលើកឡើងកាលពីមុននៅក្នុង**របាយការណ៍បន្ថែម**របស់ខ្ញុំ ស្តីពីការបោះឆ្នោត ហើយដែលបានដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សកាលពីខែកញ្ញា ឆ្នាំមុន [A/HRC/39/73/Add.1]។

**គណនេយ្យភាព**

គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងបទដ្ឋានសិទ្ធិមនុស្ស តម្រូវឱ្យមានគណនេយ្យភាពក្នុងទម្រង់នៃការលើកស្ទួយតម្លាភាព និងសុចរិតភាពនៅក្នុងការធ្វើសេចក្តីសម្រេច, ព័ត៌មាន និងថវិកា, ការប្រយុទ្ធប្រឆាំងនឹងអំពើស៊ីសំណូកសូកប៉ាន់និងអំពើពុករលួយ, ការលើកស្ទួយភាពជាអ្នកដឹកនាំប្រកបដោយការទទួលខុសត្រូវ, និងការធានាឱ្យមានការទទួលបានយុត្តិធម៌ស្មើៗគ្នា សម្រាប់មនុស្សទាំងអស់។ នៅក្នុងករណីនេះ **ខ្ញុំសូមលើកទឹកចិត្តយ៉ាងខ្លាំងក្លាដល់រាជរដ្ឋាភិបាល ឱ្យដាក់បញ្ចូលនូវផែនការ ចំណុចដៅ និងសូចនាករដ៏រឹងមាំ ទាក់ទនឹងគោលដៅអភិវឌ្ឍន៍ទី ១៦ ទៅក្នុងផែនការ មូលដ្ឋានរូបនីយកម្មរបស់ខ្លួន។**

ជំនួយផ្លូវច្បាប់ដែលអាចរកបានសំរាប់អ្នកដែលមានតម្រូវការ គឺជាជំហានដ៏មានសារសំខាន់មួយ ក្នុងការធានាសិទ្ធិទទួលបានសេវាយុត្តិធម៌សំរាប់ទាំងអស់គ្នា។ ក្នុងករណីនេះ វឌ្ឍនភាពក្នុងការបង្កើត**គោលនយោបាយជំនួយផ្នែកច្បាប់សំរាប់ជនក្រីក្រ** តាមរយៈដំណើរការតាក់តែងដែលមានលក្ខណៈពិគ្រោះយោបល់ និងការចូលរួម កំពុងតែទទួលបានការលើកទឹកចិត្ត ហើយខ្ញុំទន្ទឹងរង់ចាំពីការអនុម័តឱ្យបានឆាប់នូវគោលនយោបាយនេះ។ ខ្ញុំក៏សូមស្វាគមន៍ផងដែរដល់ការបង្កើនថវិកាសំរាប់ជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ ហើយខ្ញុំនៅតែលើកទឹកចិត្តឱ្យមានការបង្កើនឡើងឱ្យបានច្រើនថែមទៀត ដែលជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ កាន់តែជួយបម្រើដល់មនុស្សទាំងអស់ ដែលត្រូវការវា នៅក្នុងអនាគតឆាប់ៗនេះ។ ក្រសួងយុត្តិធម៌ បានជម្រាបជូនអំពីផែនការបង្កើតសាលាឧទ្ធរណ៍ថ្នាក់តំបន់ និង

មណ្ឌលសេវាកម្មច្បាប់នៅថ្នាក់ស្រុក ដែលខ្ញុំជឿជាក់ថានឹងជួយនាំសេវាយុត្តិធម៌ឱ្យកាន់តែខិតជិតប្រជាជននៅទូទាំងប្រទេស។

ស្របគ្នានេះដែរ សិទ្ធិទទួលបានសេវាយុត្តិធម៌ ក៏ទាមទារឱ្យមានសវនាការបានឆាប់រហ័ស ហើយខ្ញុំបារម្ភពីពេលវេលាដែលត្រូវបើកសវនាការ និងចំនួនដ៏ច្រើនលើសលុបនៃអ្នកជាប់ឃុំបណ្ដោះអាសន្ននៅក្នុងពន្ធនាគារ។ **ខ្ញុំសូមលើកឡើងវិញពីអនុសាសន៍របស់ខ្ញុំ ចំពោះការប្រើប្រាស់ការឃុំខ្លួនបណ្ដោះអាសន្ន តែនៅពេលណាចាំបាច់បំផុត ស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, ការ ចង ក្រងដោយប្រុងប្រយ័ត្នពីការប្រើប្រាស់ការឃុំខ្លួនបណ្ដោះអាសន្ន និងការពិនិត្យឡើងវិញឱ្យបាន ទៀងទាត់ពីតម្រូវការចាំបាច់ក្នុងការប្រើប្រាស់ការឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងករណីនីមួយៗ។**

ខ្ញុំសូមធ្វើការកត់សម្គាល់អំពីការលើកលែងទោសដោយព្រះមហាក្សត្រដល់ទណ្ឌិតមួយចំនួន រួមទាំងសមាជិកគណបក្សប្រឆាំង ហើយខ្ញុំក៏នៅតែមានការព្រួយបារម្ភចំពោះការកាត់ទោសព្យួរក្នុងករណីអ្នកស្រី ទេព វន្នី និងករណីរបស់បុគ្គលិកអង្គការអាដហុក។ ខ្ញុំក៏នៅតែមានកង្វល់ពីការឃុំខ្លួនលោក កឹម សុខា ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលសិទ្ធិ និងសេរីភាពរបស់គាត់ត្រូវបានរឹតត្បិត អស់ពេលជាង ១៤ ខែហើយ ក្រោយពីការចាប់ខ្លួន និងបន្ទាប់ពីការជាប់ឃុំនៅពន្ធនាគារជាងមួយឆ្នាំ។ **ខ្ញុំសូមអំពាវនាវឱ្យមានការលើកលែងការផ្ដន្ទាទោសដល់អ្នកស្រី ទេព វន្នី និងមន្ត្រីអាដហុក និងអតីតបុគ្គលិកនៃអង្គការនេះ។ ខ្ញុំនៅតែព្រួយបារម្ភអំពីការបទចោទដែលនៅបន្តធ្វើឡើងប្រឆាំងនឹងអតីតអ្នកកាសែតវិទ្យុអាស៊ីសេរី។ ខ្ញុំក៏សូមអំពាវនាវឱ្យមានការដោះលែងលោក កឹម សុខា ពីការឃុំឃាំងដ៏រឹតត្បិត និងបញ្ចប់ការស៊ើបអង្កេតឱ្យបានឆាប់នៅក្នុងសំណុំរឿងរបស់គាត់ ដើម្បីធានាពីសិទ្ធិរបស់គាត់ក្នុងការទទួលបានការកាត់ក្ដីប្រកបក្នុងរយៈពេលសមស្របមួយ ដោយឈរលើការវាយតម្លៃពីភស្តុតាងមួយច្បាស់លាស់ និងមានតម្លាភាព ឬបើមិនដូច្នេះទេ ត្រូវទំលាក់ចោលនូវបទចោទប្រកាន់ប្រឆាំងនឹងលោក។**

**ស្ថាប័ន**ដែលមានលក្ខណៈតម្លាភាព និង គណនេយ្យភាព គឺចាំបាច់ត្រូវសម្រេចឲ្យបាននូវអភិបាលកិច្ចល្អ។ ខ្ញុំសូមស្វាគមន៍ចំពោះសេវាកម្មច្រកចេញចូលតែមួយនៅថ្នាក់ក្រោមជាតិ ហើយជាពិសេសគឺការបង្កើតការិយាល័យប្រជាពលរដ្ឋ ដើម្បីទទួលពាក្យបណ្ដឹងពាក់ព័ន្ធនឹងសេវាសាធារណៈ។ ទាំងនេះគឺជាជំហានសំខាន់ៗក្នុងការទទួលបាននូវសេវាកម្មប្រកបដោយប្រសិទ្ធភាព និងគណនេយ្យភាពខ្ពស់នៅថ្នាក់ក្រោមជាតិ។ កិច្ចពិភាក្សារបស់ខ្ញុំជាមួយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទាក់ទងទៅនឹងការងារគ្រប់គ្រងថវិកា និង លក្ខណ្ឌតម្រូវសម្រាប់ក្រសួងផ្សេងៗ ក្នុងការដាក់ជូនផែនការថវិកាច្បាស់លាស់ សម្រាប់ការចំណាយរបស់ពួកគេគឺជារឿងដែលគួរឲ្យលើកទឹកចិត្ត។

ទោះជាយ៉ាងណាក៏ដោយ កិច្ចខិតខំប្រឹងប្រែងច្រើនថែមទៀតគឺជាកត្តាចាំបាច់។ ខ្ញុំសូមអំពាវនាវដល់ក្រសួងយុត្តិធម៌ ដើម្បីធានាថា ថ្លៃសេវាទាំងអស់ពាក់ព័ន្ធនឹងតុលាការ ត្រូវបានបិទផ្សាយនៅក្នុង

តុលាការទាំងអស់ នៅទីកន្លែងណាដែលសាធារណជនអាចមើលឃើញយ៉ាងច្បាស់ និង តាមវិធីណាដែលការបិទផ្សាយទាំងនោះមិនអាចត្រូវបានដកចេញដោយងាយបាន។ ខ្ញុំក៏សូមអំពាវនាវផងដែរដល់**ក្រសួងយុត្តិធម៌ និង ស្ថាប័នតុលាការ**ឱ្យបំពេញការងាររបស់ខ្លួនប្រកបដោយតម្លាភាពបន្ថែមទៀតទាក់ទងនឹងប្រតិបត្តិការរបស់ពួកគេ រួមទាំងលក្ខណវិនិច្ឆ័យ និង វិធីសាស្ត្រដែលត្រូវបានប្រើប្រាស់ ដើម្បីសម្រេចលើការតំឡើងតំណែង និង ការផ្ទេរចៅក្រម និង ព្រះរាជអាជ្ញា ហើយនិងចាត់វិធានការយ៉ាងសកម្មថែមទៀត ដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយ និងពង្រឹងឯករាជ្យភាពនិងភាពមិនលំអៀងរបស់តុលាការ។

**ទិន្នន័យ និង ភ័ស្តុតាង**ផ្តល់នូវមធ្យោបាយចាំបាច់ ដើម្បីជួយដល់ស្ថាប័នក្នុងការទទួលខុសត្រូវជាសាធារណៈ និងធានាថា គោលនយោបាយនិងកម្មវិធីនានាកំពុងជួយជ្រោមជ្រែងដល់មនុស្សគ្រប់ស្រទាប់ទាំងអស់ក្នុងសង្គម រួមបញ្ចូលទាំងអ្នកទាំងឡាយណាដែលទំនងជាត្រូវគេបោះបង់ចោល។ ក្នុងន័យនេះ ខ្ញុំបានជួបជាមួយក្រសួងផែនការ និង វិទ្យាស្ថានជាតិស្ថិតិ និងបានគូសបញ្ជាក់អំពីសារៈសំខាន់នៃទិន្នន័យ និងការបែងចែកប្រភេទនៃទិន្នន័យទាំងនោះ។ ប្រឈមមុខទៅនឹងបញ្ហាដែលទាក់ទងនឹងសមត្ថភាព ខ្ញុំសូមលើកទឹកចិត្តដល់វិទ្យាស្ថានជាតិស្ថិតិក្នុងការស្វែងរកជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍នានា ដើម្បីជួយក្នុងការប្រមូល និង ការបំបែកទិន្នន័យដែលត្រូវការ ដើម្បីវាស់វែងឱ្យឃើញថាការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជា ពិតជាមិនទុកនរណាម្នាក់ចោលឡើយ។

គណនេយ្យភាពក៏មានសារសំខាន់ផងដែរ នៅកម្រិតអន្តរជាតិ។ នៅខែមករា ឆ្នាំ២០១៩ ប្រទេសកម្ពុជានឹងទទួលបានការពិនិត្យឡើងវិញតាមកាលកំណត់ជាសកលលើកទី ៣ ចំពោះការអនុវត្តសិទ្ធិមនុស្សរបស់ខ្លួន នៅចំពោះមុខក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប នៅទីក្រុងហ្សឺណែវ។ ប្រទេសកម្ពុជាក៏មានលទ្ធភាពក្នុងការដាក់ស្នើរបាយការណ៍ជាតិស្ម័គ្រចិត្តផងដែរ ស្តីពីការអនុវត្តរបស់ខ្លួននៅក្រោមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ទៅកាន់វេទិកានយោបាយជាន់ខ្ពស់របស់អង្គការសហប្រជាជាតិដែលនឹងជួបប្រជុំគ្នានៅអំឡុងខែកក្កដា ឆ្នាំ២០១៩។ ខ្ញុំសូមលើកទឹកចិត្តដល់រដ្ឋាភិបាលឱ្យធ្វើការងារដោយបើកចំហជាមួយការពិនិត្យបំពេញបន្ថែមទាំងពីរនេះ ដើម្បីទទួលបានអត្ថប្រយោជន៍យ៉ាងប្រសើរពីការវាយតម្លៃ ដោយរដ្ឋសមាជិកផ្សេងទៀត។ **ខ្ញុំសូមផ្តល់អនុសាសន៍ឱ្យរដ្ឋាភិបាលរៀបចំសន្និសីទថ្នាក់ជាតិមួយ ជាមួយអង្គការសហប្រជាជាតិ និង សង្គមស៊ីវិល ដើម្បីតាមដាននិងធ្វើការងារបន្តបន្ទាប់ពីការពិនិត្យឡើងវិញទាំងនេះ។**

ស្មារតីនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ជួនកាលត្រូវបានសង្ខេបនៅក្នុងការប្តេជ្ញាចិត្តទាំងស្រុងថាគ្មានមនុស្សណាម្នាក់ត្រូវបានទុកចោល ហើយវាជាការឆ្លុះបញ្ចាំងនូវបទដ្ឋានសិទ្ធិមនុស្សស្តីពីគោលការណ៍មិនរើសអើង។ នៅក្នុងបេសកកម្មមុនៗ ខ្ញុំបានផ្តោតលើក្រុមដែលត្រូវបានគេបោះបង់ចោល ហើយបានរាយការណ៍ទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្សអ.ស.ប ស្តីពីមនុស្សងាយរងគ្រោះដែលត្រូវបានគេទុកចោល៖ រួមមានកុមារ ជនទេសន្តរប្រវេសន៍ ស្ត្រី ជនជាប់ឃុំ អ្នកប្រើប្រាស់គ្រឿងញៀនដែលនៅជាប់ញៀនមិនទាន់ផ្តាច់បាន ជនជាតិភាគតិច រាប់បញ្ចូលទាំងជនជាតិដើមភាគតិច ជនដែលមានពិការភាព។ ខ្ញុំក៏បានគូសបញ្ជាក់ផងដែរអំពីហានិភ័យ ទាក់ទងទៅនឹងមូលហេតុនានានៃការរើសអើងដែលបង្កើត និងពង្រីកឱ្យមានឧបសគ្គសម្រាប់មនុស្សទាំងនោះ។

ដើម្បីធានាឱ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ប្រទេសកម្ពុជាត្រូវចាត់វិធានការដើម្បី**ផ្តល់សិទ្ធិអំណាចដល់ក្រុមដែលងាយរងគ្រោះ និងលុបបំបាត់រាល់ការរើសអើងទាំងអស់**។ ជាថ្មីម្តងទៀតខ្ញុំបានកត់សម្គាល់ឃើញថា តំណែងជាន់ខ្ពស់របស់ស្ត្រីនៅក្នុងជួររដ្ឋាភិបាលនៅតែមានកង្វះខាតនៅពេលខ្ញុំបានជួបប្រជុំជាមួយក្រសួងនិងស្ថាប័នជាច្រើន។ ការកត់សម្គាល់ជាវិជ្ជមានមួយទៀតគឺនៅក្នុងកិច្ចប្រជុំរបស់ខ្ញុំជាមួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ខ្ញុំបានស្វែងយល់អំពីវឌ្ឍនភាពក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្ម។ គោលដៅអភិវឌ្ឍន៍ទី១៦ មានចំណុចដៅមួយជាក់លាក់ដែលផ្តោតទៅលើការផ្តល់អត្តសញ្ញាណកម្មផ្លូវច្បាប់សម្រាប់មនុស្សទាំងអស់គ្នា រួមទាំងការចុះបញ្ជីកំណើត ដែលជាស្នូលនៃសិទ្ធិមនុស្ស។ រដ្ឋាភិបាលបានផ្តល់ព័ត៌មានបច្ចុប្បន្នភាពដល់ខ្ញុំ ទាក់ទងនឹងអាទិភាពថវិការបស់រដ្ឋាភិបាល ជាពិសេសការបង្កើនថវិកាសម្រាប់វិស័យសង្គម។

ក្នុងអំឡុងពេលនៃបេសកកម្មនេះ ខ្ញុំបាន**ធ្វើដំណើរ**ទៅកាន់ខេត្តកំពង់ឆ្នាំងដើម្បីធ្វើការស៊ើបអង្កេតទាក់ទងនឹងផែនការរបស់អាជ្ញាធរខេត្ត ដើម្បីផ្លាស់ទីតាំងរបស់មនុស្សជាងមួយម៉ឺននាក់ដែលកំពុងរស់នៅក្នុងភូមិអណ្តែតទឹក ឱ្យទៅរស់នៅលើតំបន់ដីគោកជាអចិន្ត្រៃយ៍។ សកម្មភាពនេះរួមបញ្ចូលនូវបញ្ហាសិទ្ធិមនុស្សផ្សេងៗបូករួមនឹង គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពមួយចំនួន ហើយវាជារឿងស្មុគស្មាញដែលចៀសមិនរួច។ ជាការពិតណាស់ យើងត្រូវការធ្វើអោយប្រសើរឡើងនូវគោលដៅអភិវឌ្ឍន៍ទី ៦  (ទឹក និងអនាម័យ) និងត្រូវការពារ និងប្រើប្រាស់ប្រកបដោយចីរភាពនូវទឹកនិងធនធានធម្មជាតិនៅបឹងទន្លេសាបនិង ទន្លេនានា (គោលដៅអភិវឌ្ឍន៍ទី ១៤ - ជីវិតនៅខាងក្រោមទឹក)។ អាជ្ញាធរខេត្តក៏ទទួលស្គាល់ផងដែរនូវតម្រូវការដើម្បីធានាថាផែនការតាំងទីលំនៅថ្មីនេះ នឹងមិនធ្វើឱ្យប្រជាជនកាន់តែមានសភាពកាន់តែយ៉ាប់យឺននោះទេ  ដែលអាចជាការអនុវត្តផ្ទុយទៅនឹងកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ (គោលដៅអភិវឌ្ឍន៍ទី ១ - បញ្ចប់ភាពក្រីក្រ)។ ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ខ្លះស្ថិតក្នុងចំណោមអ្នកក្រីក្របំផុត នៅក្នុងតំបន់នោះ។ ភាគច្រើននៃ

ពួកគេមិនមានឯកសារសម្គាល់អត្តសញ្ញាណ ដែលអនុញ្ញាតឱ្យពួកគេទទួលបានសេវា និងសិទ្ធិ ជាមូលដ្ឋានសមស្របនានា (គោលដៅអភិវឌ្ឍន៍ទី ១៦)។

ខណៈពេលដែលខ្ញុំបានធ្វើទស្សនកិច្ចទៅកាន់**ទីតាំងថ្មី**ជាច្រើននៅក្នុងប្រទេសកម្ពុជា ដែលជារឿយៗមានការពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ច នេះជាលើកដំបូងហើយដែលខ្ញុំបានទៅមើលតំបន់មួយនៅលើដីដែលគេបានរៀបចំឡើងវិញ សម្រាប់ឱ្យសហគមន៍ធ្វើការបន្លាស់ទីចេញពីទឹកដើម្បីទៅរស់នៅលើដីនោះ។ ខ្ញុំបានទៅតំបន់មួយដែលមានវឌ្ឍនភាពល្អឆ្ពោះទៅរកការផ្តល់ហេដ្ឋារចនាសម្ព័ន្ធសមស្របសម្រាប់អ្នកដែលនឹងរស់នៅលើដីនោះ (ផ្លូវថ្នល់ ទីតាំងអចិន្ត្រៃយ៍សម្រាប់សង់ផ្សារ លទ្ធភាពប្រកបរបរជំនួសផ្សេងៗ អគ្គិសនី និងទឹកស្អាត)។ អាជ្ញាធរខេត្តកំពុងធ្វើការជាដៃគូជាមួយក្រុមហ៊ុនឯកជនមួយក្នុងការរៀបចំទីតាំងនេះ។ តំបន់ផ្សេងៗទៀតដែលខ្ញុំបានធ្វើទស្សនកិច្ចមានដូចជា តំបន់ឆ្នុកទ្រូ និងដំបូកកកោះ គឺមានការអភិវឌ្ឍន៍តិចតួច ហើយទឹកមិនទាន់ស្រកអស់ចេញពីតំបន់តាំងទីលំនៅនោះនៅឡើយ។ ទោះជាយ៉ាងនេះក្តី អាជ្ញាធរខេត្តបន្តធ្វើការងារជាមួយសហគមន៍ដើម្បីធានាថា ពួកគេប្តូរទីតាំងទៅកាន់ដីសមស្របដោយមានហេដ្ឋារចនាសម្ព័ន្ធ សម្រាប់ការរស់នៅ និងធានាការប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគេ។

ក្តីព្រួយបារម្ភដែលបានលើកឡើងដោយប្រជាពលរដ្ឋនៅសហគមន៍អណ្តែតទឹកក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចរបស់ខ្ញុំ បានបន្ទរក្តីព្រួយបារម្ភទាំងនោះដែលធ្លាប់ឮនៅក្នុងបេសកកម្មរបស់ខ្ញុំនាពេលកន្លងមក ក៏ដូចជាក្តីព្រួយបារម្ភទាក់ទងនឹង**សិទ្ធិដីធ្លី** ដែលមានបញ្ជាក់នៅក្នុងញត្តិមួយចំនួនដែលខ្ញុំទទួលបានក្នុងអំឡុងពេល ១០ ថ្ងៃ កន្លងមកនេះ។ គោលដៅអភិវឌ្ឍន៍ទី ១ ស្តីពីការកាត់បន្ថយភាពក្រីក្រ សំដៅទៅលើសិទ្ធិស្មើគ្នាចំពោះធនធានសេដ្ឋកិច្ច និងសិទ្ធិទទួលបានដីធ្លី និងធនធានធម្មជាតិ។ **ខ្ញុំសូមអំពាវនាវឱ្យរដ្ឋាភិបាលកែលម្អនូវមធ្យោបាយទាំងឡាយដើម្បីដោះស្រាយបញ្ហាសិទ្ធិដីធ្លីដ៏ស្មុគស្មាញតាមរយៈអភិក្រមគ្រប់ជ្រុងជ្រោយ និងប្រកបដោយតម្លាភាព និងភាពត្រឹមត្រូវ ដើម្បីដោះស្រាយវិវាទដីធ្លី និងការតាំងទីលំនៅ**។ មានតែតាមរយៈមធ្យោបាយនេះទេ ទើបគ្មាននរណាម្នាក់ត្រូវបានគេបោះបង់ចោលឡើយ។

* * *

បេសកកម្មនេះកើតមានឡើងនៅចំពេលដ៏សំខាន់ ដែលប្រទេសកម្ពុជាទើបបានអនុម័តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ ហើយនិងក្របខ័ណ្ឌនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ប្រសិនបើប្រទេសកម្ពុជាត្រូវបន្តលើវិថីនៃការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាពរបស់ខ្លួន រដ្ឋាភិបាលត្រូវធ្វើការងារដើម្បីឆ្លុះបញ្ចាំងពីឆន្ទៈរបស់ប្រជាពលរដ្ឋ កសាងស្ថាប័នដែលឆ្លើយតបទៅនឹងសិទ្ធិរបស់ប្រជាពលរដ្ឋ និងកសាងមនុស្សដែលមានជំនាញចាំបាច់ ហើយដែលអាចមានសំឡេង និងអាចចូលរួមយ៉ាងសកម្មនៅក្នុងការអភិវឌ្ឍ និងក្នុងសង្គម។ នេះមានន័យថា

យើងត្រូវតែរក្សាសិទ្ធិមនុស្សជាជាចំណុចស្នូលដ៏សំខាន់នៃយុទ្ធសាស្ត្រជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងសន្តិភាពស្ថិតស្ថេរយូរអង្វែង។ រដ្ឋធម្មនុញ្ញ បទដ្ឋានសិទ្ធិមនុស្សនានា និង គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពមានផ្តល់នូវមធ្យោបាយផ្សេងៗដើម្បីសម្រេចកាងារខាងលើនេះ។

**ចប់**

***លោកស្រីសាស្ត្រាចារ្យ រ៉ូណា ស្មីត*** *(ចក្រភពអង់គ្លេស) ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងជាអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅប្រទេសកម្ពុជា ក្នុងខែមីនា ឆ្នាំ២០១៥ ។ ក្នុងនាមជាអ្នករាយការណ៍ពិសេស លោកស្រីគឺជាផ្នែកមួយនៃអ្វីដែលគេស្គាល់ថាជានីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីពិសេស (ស្ថាប័នដ៏ធំបំផុតមួយនៃអ្នកជំនាញឯករាជ្យនៅក្នុងប្រព័ន្ធសិទ្ធិមនុស្ស អ.ស.ប) គឺជាឈ្មោះទូទៅមួយនៃយន្តការឯករាជ្យសម្រាប់ឃ្លាំមើលនិងស្វែងរកការពិត របស់ក្រុមប្រឹក្សានេះ។ អ្នកកាន់អាណត្តិនីតិវិធីពិសេស គឺជាអ្នកជំនាញឯករាជ្យផ្នែកសិទ្ធិមនុស្ស ដែលក្រុមប្រឹក្សាសិទ្ធិមនុស្សបានតែងតាំងឡើង ដើម្បីធ្វើការងារពាក់ព័ន្ធនឹងស្ថានភាពសិទ្ធិមនុស្សរបស់ប្រទេសណាមួយជាក់លាក់ ឬបញ្ហាសិទ្ធិមនុស្សតាមវិស័យនីមួយៗ នៅគ្រប់តំបន់ទាំងអស់លើពិភពលោក។ ពួកគាត់មិនមែនជាបុគ្គលិករបស់ អ.ស.ប ទេ ហើយធ្វើការឯករាជ្យពីរដ្ឋាភិបាល និង អ.ស.ប។ ពួកគាត់បំពេញការងារក្នុងសមត្ថភាពបុគ្គលផ្ទាល់របស់ខ្លួន ហើយមិនទទួលប្រាក់បៀវត្សរ៍លើការងារនេះឡើយ។*

ឧបសម្ព័ន្ធ

**គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជា**

គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជា (CSDGs) រួមបញ្ចូលនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ជាសកល ដែលមានចំនួន ១៧ គោលដៅ ហើយត្រូវបានបន្ថែមដោយគោលដៅទី ១៨ ស្តីពីសកម្មភាពកំចាត់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម សម្រាប់ប្រទេសកម្ពុជា។ ចំណុចដៅទាំងឡាយនៅថ្នាក់ជាតិបាននិងកំពុងត្រូវរៀបចំក្នុងផ្នែកមួយនៃដំណើរការតាក់តែងផែនការមូលដ្ឋានរូបនីយកម្មនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។



**<u>គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី១៦ របស់អ.ស.បៈ សន្តិភាព យុត្តិធម៌ និងស្ថាប័នរឹងមាំ</u>**

**គោលដៅទី១៦៖** លើកកម្ពស់សង្គមដែលមានសន្តិភាពប្រកបដោយបរិយាបន្ន ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព, ផ្តល់នូវការទទួលបានយុត្តិធម៌សម្រាប់មនុស្សគ្រប់រូប និងដើម្បីកសាងស្ថាប័នដែលមានប្រសិទ្ធភាព គណនេយ្យភាព និងបរិយាបន្ននៅគ្រប់កម្រិតទាំងអស់។

**ចំណុចដៅនៃគោលដៅទី១៦ (ចំណុចដៅសកល)៖**

១៦.១ កាត់បន្ថយឲ្យបានច្រើនរាល់ទម្រង់នៃអំពើហិង្សា និងអត្រាមរណភាពដោយអំពើហិង្សានៅគ្រប់ទីកន្លែង។

១៦.២ លុបបំបាត់ការរំលោភបំពាន ការធ្វើអាជីវកម្ម ការជួញដូរ និងរាល់ទម្រង់នៃអំពើហិង្សានិងទារុណកម្មទៅលើកុមារ។

១៦.៣ លើកកម្ពស់វិធានការច្បាប់នៅកម្រិតជាតិនិងអន្តរជាតិ និងធានាការទទួលបានយុត្តិធម៌ស្មើភាពគ្នាសម្រាប់មនុស្សគ្រប់រូប។

១៦.៤ ត្រឹមឆ្នាំ២០៣០ កាត់បន្ថយឲ្យបានច្រើននូវលំហូរហិរញ្ញវត្ថុនិងគ្រឿងសព្វាវុធខុសច្បាប់ ពង្រឹងការប្រមូលនិងការប្រគល់នូវទ្រព្យដែលត្រូវបានលួច និង ប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មដែលមានការចាត់តាំងគ្រប់ទម្រង់។

១៦.៥ កាត់បន្ថយឲ្យបានច្រើន រាល់ទម្រង់នៃអំពើពុករលួយនិងអំពើស៊ីសំណូកសូកប៉ាន់។

១៦.៦ រៀបចំស្ថាប័នឲ្យមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៅគ្រប់កម្រិត។

១៦.៧ ធានាឱ្យមានការធ្វើសេចក្តីសម្រេចប្រកបដោយលក្ខណៈឆ្លើយតប បរិយាបន្ន ចូលរួមនិងភាពជាតំណាងនៅគ្រប់កម្រិត។

១៦.៨ បើកទូលាយនិងពង្រឹងការចូលរួមរបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ នៅក្នុងស្ថាប័នអភិបាលកិច្ចសកលនានា។

១៦.៩ ត្រឹមឆ្នាំ២០៣០ ផ្តល់អត្តសញ្ញាណកម្មផ្លូវច្បាប់ដល់មនុស្សគ្រប់រូប រួមទាំង ការចុះបញ្ជីកំណើត។

១៦.១០ ធានាការទទួលបានជាសាធារណៈនូវព័ត៌មាន និងការការពារសិទ្ធិសេរីភាពមូលដ្ឋានឲ្យស្របតាមច្បាប់ជាតិ និងកិច្ចព្រមព្រៀងអន្តរជាតិ។

**មធ្យោបាយអនុវត្តគោលដៅទី១៦**

១៦.ក ពង្រឹងបណ្តាស្ថាប័នជាតិពាក់ព័ន្ធ រួមទាំងតាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បីកសាងសមត្ថភាពនៅគ្រប់កម្រិត ជាពិសេស នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ សម្រាប់ទប់ស្កាត់អំពើហិង្សា និងការប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្មនិងឧក្រិដ្ឋកម្ម។

១៦.ខ លើកកម្ពស់និងជំរុញការអនុវត្តច្បាប់និងគោលនយោបាយស្តីពីការមិនរើសអើងដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព។